# ❤️ដូចជាខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ❤️
## យ៉ូហាន ១៥:៩-១៧

YouTube https://youtu.be/H--OT75iN3U

**ប្រធានបទ:** ព្រោះព្រះយេស៊ូស្រលាញ់យើងរាល់គ្នា ដូច្នេះយើងគួរតែស្រលាញ់អ្នកដទៃដែរ!

**ខគម្ពីចងចាំ** (អ្នកអាចអោយប្អូនៗទន្ទេញខគម្ពីរនេះ)
យើងនិងផ្តោតទៅលើយ៉ូហានជំពូក១៥:១២"នេះជាបញ្ញាត្តិរបស់ខ្ញុំ គឺអោយអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"

### សេចក្តីផ្តើម

តើប្អូនស្រឡាញ់អ្វីខ្លះនៅក្នុងជីវិតរបស់ប្អូន? តើប្អូនស្រឡាញ់ប៉ាម៉ាក់ប្អូនដែរឬទេ? ស្រលាញ់មិត្តភក្រ្តប្អូនដែរឬទេ? ស្រលាញ់របស់លេងរបស់ប្អូនដែរឬទេ? ហើយតើប្អូនចូលចិត្តអាហាររបស់ប្អូនដែរឬទេ?មិនថាប្អូនស្រឡាញ់អ្វីទេ ខ្ញុំជឿជាក់ថាប្អូនធ្លាប់ខកចិត្តដោយសារសេចក្តីស្រឡាញ់ទាំងអស់នោះដែរ។ពេលខ្លះប្អូនខកចិត្តដោយសារមិត្តភក្រ្តធ្វើអោយប្អូនឈឺចាប់ឬខកចិត្តដោយសារប៉ាម៉ាក់ស្រែកគំហ៊កអោយឬខកចិត្តដោយសារអាហារមិនឆ្ងាញ់ ឬដោយសាររបស់លេងប្អូនខូច។

### សារចំណាំ:

ប៉ុន្តែទំនាក់ទំនងដ៏សំខាន់មួយដែលយើងមានគឺការសន្យាដែលនឹងមិនធ្វើអោយយើងខកចិត្ត..នោះគឺមិត្តភាពយើងជាមួយព្រះយេស៊ូវ! ស្តាប់ទៅវាដូចជាចំលែកបន្តិចដែលគិតថាព្រះអង្គជាមិត្តសម្លាញ់ យើងមិនបានជួបព្រះអង្គផ្ទាល់ ឬមិនបាននិយាយទូរសព្ទ័ជាមួយទ្រង់ តែព្រះយេស៊ូវនៅតែហៅយើងថាជាមិត្តសម្លាញ់របស់ទ្រង់។ អង្គមានបន្ទូលទៅកាន់សាវក័ទ្រង់ថាពួកគេមិនមែនជាអ្នកបំរើទេតែពួកគេជាមិត្តសម្លាញ់របស់ ទ្រង់ហើយពួកគេគួរ តែនៅជាប់ជាមួយនឹងក្តីស្រលាញ់របស់ទ្រង់ហើយត្រូវស្រលាញ់គ្នាទៅវិញទៅមក។ ត្រូវហើយឥឡូវនេះយើងជាសាវ័ករបស់ទ្រង់ ហើយព្រះយេស៊ូវចង់អោយយើងចែករំលែកក្តីស្រលាញ់របស់ទ្រង់ និងអោយយើងសំរាកនៅក្នុងមិត្តភាពរបស់ទ្រង់ព្រះយេស៊ូវមានព្រះបន្ទូលថាក្តីស្រលាញ់ដ៏អស្ចារ្យសំរាប់នរណាម្នាក់នោះគឺការលះបង់ជីវិតរបស់ខ្លួនដើម្បីមិត្តសម្លាញ់នោះ។ ស្តាប់ទៅដូចជាជ្រុលបន្តិច...ប៉ុន្តែវាពិតដូចជាអ្វីដែលព្រះយេស៊ូវ បានធ្វើសំរាប់យើងទាំងអស់គ្នា! យើងអាចជឿជាក់លើសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើងបានពីព្រោះយើងដឹងថាទ្រង់បានសុគតសំរាប់ពួកយើង។ ពេលខ្លះយើងកើតទុក្ខដោយសារតែទំនាក់ទំនង យើងជាមួយអ្នកផ្សេងអាចធ្វើអោយយើងខកចិត្តពេលខ្លះ

គេអាចធ្វើអោយយើងខឹង ហើយធ្វើបាបចិត្តយើង។ ប៉ុន្តែព្រះយេស៊ូវមិនដែលចាកចោលយើងទេទ្រង់ស្រលាញ់យើងទ្រង់គឺជាទំនាក់ទំនងដ៏ល្អជាងគេដែលយើងមាន បើទោះបីជាយើងមិនបានជួបទ្រង់ផ្ទាល់ក៏ដោយក៏យើងអាចអធិស្ឋាន ហើយអានព្រះគម្ពី និងជជែកជាមួយអ្នកផ្សេង ទៀតដែល គេស្គាល់ ទ្រង់។

## ការអនុវត្តន៍:

តើប្អូនដឹងពីអ្វីផ្សេងទៀតដែរឬទេ? ព្រះយេស៊ូវចង់អោយយើងចេះស្រលាញ់គ្នាទៅវិញទៅមក ការព្យាយាមធ្វើល្អ និងយកចិត្តទុកដាក់របស់មនុស្សអាចនឹងបរាជ័យ តែយើងអាចទុកចិត្តលើទ្រង់ដើម្បីឲ្យទ្រង់ធ្វើការនៅក្នុងជីវិតយើងក្នុងការបង្ហាញសេចក្តីស្រលាញ់។ ព្រះយេស៊ូវមានបន្ទូលថាបើសិនយើងស្រលាញ់ទ្រង់យើងនិងបង្ហាញតាមរយៈការរក្សាទំនាក់ទំនងជាប់ជាមួយទ្រង់ និងតាមរយៈការចែករំលែកក្តីស្រលាញ់របស់ទ្រង់ជាមួយមនុស្សនៅជុំវិញខ្លួនយើង។ យើងបង្ហាញពីសន្តានចិត្តល្អ ចារិតសុភាពរាបសារ និងការស្តាប់អ្នកដទៃ ហើយជួយអ្នកដទៃ យើងអាចអោយពន្លឺរបស់ព្រះយេស៊ូវបានភ្លឺឡើងនៅក្នុងជីវិតយើង។ យើងអាចបង្ហាញថា យើងមានទំនាក់ទំនងជាមួយទ្រង់ដោយការយកចិត្តទុកដាក់ចំពោះទំនាក់ទំនងរបស់យើងនៅលើផែនដី។ ចូរចងចាំថាទ្រង់គឺជាមិត្តសម្លាញ់យ៉ាងអស្ចារ្យសំរាប់យើងគ្រប់គ្នា។ ទោះជាយើងមិនល្អគ្រប់លក្ខ័ក៏ដោយក៏ទ្រង់នៅតែទ្រង់ស្រលាញ់យើង ហើយស៊ូសុគត់សំរាប់យើងទ្រង់ជាគំរូដ៏ល្អនៃទំនាក់ទំនងទាំងឡាយ យើងគួរតែព្យាយាមអោយអស់ពីលទ្ធភាពអោយដូចជាព្រះយេស៊ូវ។

## សូមយើងបានអធិស្ឋានទាំងអស់គ្នា:(សូមអោយប្អូនៗថាតាមឃ្លានិមួយៗ)

ឱព្រះអម្ចាស់អើយ កូនសូមអរព្រះគុណទ្រង់ដែលព្រះអង្គបានចាត់ព្រះយេស៊ូវអោយមកលើផែនដី
ទ្រង់គឺជាមិត្តសម្លាញ់ដ៏អស្ចារ្យដែលកូនមាន
សូមជួយកូននឹកចាំពីវត្តមានរបស់ព្រះអង្គ
និងចែកចាយក្តីស្រលាញ់របស់ទ្រង់ទៅកាន់មនុស្សជុំវិញកូន
អរព្រះគុណចំពោះក្តីស្រលាញ់របស់ទ្រង់ កូនស្រលាញ់ព្រះអង្គ!
នៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ អាម៉ែន!

---

## សកម្មភាព:

នេះគឺជាសកម្មភាពខ្លះៗសំរាប់មេរៀននេះ សូមគិតពីគំនិតនៃក្តីស្រលាញ់របស់ព្រះ និងការស្រលាញ់គ្នាទៅវិញទៅមកសូមឆ្លើយនឹងសំនួរទាំងអស់នេះ!

**១** តើប្អូនធ្លាប់ជួបសិស្សថ្មីៗនៅសាលាដែលគ្មាននរណានិយាយរកឫលេងជាមួយដែរឫទេ? បើជួបតើអ្វីដែលប្អូននឹងនិយាយឫធ្វើទៅកាន់ពួកគេ?នៅក្នុងព្រះគម្ពីកូរិនថូសខ្សែទី១បាននិយាយាថាក្តីស្រលាញ់គឺមាន សន្ដានចិត្តល្អ ដូច្នេះយើងគួរតែធ្វើល្អមានក្តីស្រលាញ់ហើយទទួលស្វាគមន៏សិស្សថ្មីនោះ ទោះបីគ្មាននរណាស្វាគមន៏គេក៏ដោយ

**២** តើប្អូននឹងធ្វើយ៉ាងមិចបើប្អូនមានរបស់ញ៉ាំច្រើនហើយបងប្អូនរបស់ប្អូនសុំ តើប្អូននឹងចែករំលែកដែរឫទេ? ប្រហែលកាលពីមុនបងប្អូនរបស់ប្អូនមិនចែករំលែករបស់ញ៉ាំដែលគាត់មានអោយប្អូនញ៉ាំទេ ប៉ុន្តែព្រះមានបន្ទូលថាក្តីស្រលាញ់គឺមិនអាត្មានិយមទេ ដូច្នេះប្អូនគួរគិតពីអ្នកដ៏ទៃអោយបានច្រើនជាងខ្លួនឯង

**៣** សំណួរចុងក្រោយ បើប្អូនធ្វើអោយចានបែកតើប្អូននឹងប្រាប់ប៉ាម៉ាក់ថាប្អូនជាអ្នកធ្វើបែក ឫប្អូនទំលាក់កំហុសឲសត្វឆ្កែ? តើអ្នកណាចង់អោយខ្លួនឯងមានបញ្ហា? មិនមែនខ្ញុំទេ! តែតើវានឹងមិនអីទេឬដែលប្អូននិយាយកុហាក់? មិនកើតទេព្រះគម្ពីបានប្រាប់យើងថាក្តីស្រលាញ់គឺរីករាយជាមួយនឹងការពិត

## សិប្បកម្ម

សំរាប់សិប្បកម្ម ប្អូនៗអាចកាត់ក្រដាស់ចេញជារូបបេះដូងហើយសរសេរអ្វីដែលប្អូនៗអាចបង្ហាញពីក្តីស្រលាញ់ទៅកាន់អ្នកផ្សេង បន្ទាប់មកប្អូនៗអាចបិទក្រដាស់បេះដូងទាំងនោះជាមួយគ្នាធ្វើជាកំរ៉ងផ្កា



